ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អក្សរសាស្ត្រខ្មែរ

KHMER LITERATURE

អត្ថាភិប្បាយ
ប្រឡងគ្រូបង្រៀនកម្រិតឧត្តម

ប្រែកពន៖ វិទ្យាស្ថានជាតិអប់រំ

សាស្ត្រាចារ្យ ខឹម សារិទ្ធ

Page: Khem Sarith Education

https://web.facebook.com/Khemsarithedu/

ព្រះពុទ្ធសាសនាចក្រកម្ពុជា
ក្រសួងអប់រំ យុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ

ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា + ១)ជំនាន់ទី១៨
សម័យប្រឡង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២

ឥទ្ធិសាស: ៦ភ:ឧសទី១ អក្សរសាស្ត្រខ្មែរ ។ ម៉ោង:ពេល: ១៨០នាទី តិន្ទុ: ២០/២០

អត្ថាធិប្បាយ

១. (ពិន្ទុ១)នៅក្នុងភាសាខ្មែរប្រើសញ្ញាស្រៈ៣ប្រភេទ គឺសញ្ញាស្រៈកប់តួ សញ្ញាស្រៈជាប់តួ និង
សញ្ញាស្រៈពេញតួ។ (០.៦៥)

សញ្ញាស្រៈទាំងនោះ មាន:

១. សញ្ញាស្រៈកប់តួ មាន: ុ - ូ - ិ - ី ។

ឧ: ក តក់ គ លប់... (០.៦៥)

២. សញ្ញាស្រៈជាប់តួ មាន: ា ៃ ៅ ោ ៅ ុ ូ ួ ើ ឿ ឿ ើ ៅ ៅ ោ ោ។

ឧ: ា តៀ តា គោ... (០.៦៥)

៣. សញ្ញាស្រៈពេញតួមាន: អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ។(០.៦៥)

២. (ពិន្ទុ២)សញ្ញាព្យញ្ជនៈខ្មែរជាមូលដ្ឋានមាន៣៣តួ។ ឯសញ្ញាព្យញ្ជនៈខ្មែរទាំងអស់មាន៦៦តួ។
កើតឡើងដោយការប្រើសញ្ញា-អ- និងសញ្ញា-អ-ដូចជា: (០.៥០)

-សញ្ញា-អ-ប្រើជាក់ពីលើព្យញ្ជនៈពួក-អ-មួយចំនួនឱ្យទៅជាព្យញ្ជនៈពួក-អ-មាន: ង ញ ន ម យ រ ល វ និងព្យញ្ជនៈ-ប-មួយតួឱ្យទៅជា-ប-។(០.៥០)

-សញ្ញា-អ-ប្រើជាក់ពីលើព្យញ្ជនៈពួក-អ-មួយចំនួនឱ្យទៅជាព្យញ្ជនៈពួក-អ-មាន: ប ស ហ ឡ អ។(០.៥០)

សញ្ញាព្យញ្ជនៈខ្មែរទាំងអស់នោះមាន: ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន
ប ផ ព ភ ម យ រ ល វ ស ហ ឡ អ។(០.៥០)

៣. (ពិន្ទុ២)កន្សោមនាមរីករាលបមានទម្រង់ដូចជា:


-ន + គុណបទ


-ន + ឧបបទ


-ន + កម្មបំពេញបទ


-ន + ឃ្លាគុណនាម (០.៥០)

គួសម្គែកជាដំនៃល្បះទីមួយ:ម្ល









៤. (ពិន្ទុ១)មុខងារនៃពាក្យក្នុងភាសាខ្មែរមានប្រធាន កម្មបទ គុណប្រធាន គុណបទ ឧបបទ កម្មបំពេញបទ កម្មទេសកាល កម្មភ្ជាក់ងារ និងគុណកម្មបទ។ (ប.ធ.ប)

-ឧបបទ អាចជានាម ឬកន្សោមនាម ប្រើជាធាតុសំណង់របស់កន្សោមនាម។

ឧ: ខ្ញុំ អាខ្មៅ ចូលចិត្តអង្គុយធ្នើ។(ប.ធ.ប)

-កម្មបំពេញបទ ជាកន្សោមមានភ្ជាក់ ប្រើជាធាតុសំណង់របស់កន្សោមនាម។

ឧ: ពួកគេនិតន៎រៀនសូត្រវេយ្យាករណ៍ <u>របស់ខ្មែរ</u>។(ប.ធ.ប)

៥. (ពិន្ទុ១) -ចំណាប់ចូន គឺជាការចាប់ព្យាង្គចុងចូនពីឃ្លាមួយទៅឃ្លាមួយ ពីល្បះមួយទៅល្បះមួយ។(ប.ធ.ប)

-ចួន គឺជាការប្រើស្រៈ ឬស្រៈ ផ្សំទីតាំងញាន:ប្រកបដូចគ្នា។(០.៦៥)

- ជួន គឺជាការប្រើព្យាង្គដដែលនៅក្នុងឃ្លា និងក្នុងឃ្លៈនៃកំណាព្យ។(០.៦៥)

-រណ្តំ គឺជាការប្រើព្យញ្ជន:ដើមព្យាង្គ ឬស្រៈដូចគ្នា។(០.៦៥)

៦. (ពិន្ទុ៣)កំណាព្យបទព្រហ្មគីតិ និងបទបន្ទោលកាក មានលក្ខណៈខុសគ្នាត្រង់ផ្នែកព្យ
ចំណាប់ចួន ចង្វាក់ និងបរិយាកាស។

-ផ្នែកព្យបទព្រហ្មគីតិ: ១ឃ្លៈមាន៤ឃ្លា

ឃ្លាទី១ និងឃ្លាទី៣មាន៥ព្យាង្គ

ឃ្លាទី២ និងឃ្លាទី៤មាន៦ព្យាង្គ

-ផ្នែកព្យបទបន្ទោលកាក : ១ឃ្លៈមាន៤ឃ្លា

ឃ្លាទី១ និងឃ្លាទី៣មាន៤ព្យាង្គ

ឃ្លាទី២ និងឃ្លាទី៤មាន៦ព្យាង្គ(០.៦៥)

-ចំណាប់ចួនបទព្រហ្មគីតិ

ចួនក្នុងឃ្លៈ - ៥១ = ៣២

- ៦២ = ៥៣ = ៣៤

ចួនឆ្លងឃ្លៈ ៦៤១ = ៦២២

-ចំណាប់ចួនបទបន្ទោលកាក

ចួនក្នុងឃ្លៈ - ៤១ = ៤២

- ៦២ = ៤៣ = ៤២

ចួនឆ្លងឃ្លៈ ៦៤១ = ៦២២ (០.៦៥)

-ចង្វាក់បទព្រហ្មគីតិ គេលើកដាក់សំឡេងលើព្យាង្គទី៦ ចំពោះឃ្លាមាន៥ព្យាង្គ និងព្យាង្គទី
៣ ចំពោះឃ្លាមាន៦ព្យាង្គ។

-ចង្វាក់បទបន្ទោលកាក គេលើកដាក់សំឡេងលើព្យាង្គទី៦ ចំពោះឃ្លាមាន៤ព្យាង្គ និង
ព្យាង្គទី៦ ទី៤ ចំពោះឃ្លាមាន៦ព្យាង្គ។(០.៦៥)

-បរិយាកាសបទព្រហ្មគីតិ កើតឡើងនៅសម័យអង្គរ គឺប្រើសម្រាប់សម្តែងភាពលន្ទំ
លន្ទោច ទុក្ខសោក និងការត្រាត់ត្រាស់ ប្រដៃប្រដៅ ផ្តែផ្តាំ...។

-បរិយាកាសបទបន្ទោលកាក កើតឡើងនៅសម័យអង្គរ គឺប្រើសម្រាប់ការឈ្លោះទាស់ទែង
គ្នា ការមើលងាយ ការរិះគន់ កំប្លុកកំប្លែង ទូន្មានអប់រំ...។(០.៦៥)

តែងកំណាព្យបទបន្ទោលកាក ឱ្យបានត្រឹមត្រូវ: ស្តីព័ន្ធល្អ

-១ ៦ ៣ ៥ ┌──────┐ ១ ៦ ៣ ┗ ៥ ៩ ┐
១ ៦ ៣ ៥ ┘ ១ ៦ ៣ ៥ ៩ ┐ ៧
-១ ៦ ៣ ៨ ┘ ១ ៦ ៣ ៨ ៥ ៩ ┘
១ ៦ ៣ ៨ ១ ៦ ៣ ៨ ៥ ៩ ៧

-តែងបានច្រាំល្ហះ(០.៦៥)

-មើលចូនក្នុងល្ហះ(០.៦៥)

-មើលចូនធ្វងល្ហះ(០.៦៥)

-មើលអត្ថន័យ(០.៦៥)

ជាតុកំណាល្ហះ

-ផ្ទាស់តាល្ហះ ១ល្ហះមាន៤ឃ្លា

ឃ្លាទី១ និងឃ្លាទី៣មាន៤ព្យាង្គ

ឃ្លាទី២ និងឃ្លាទី៤មាន៦ព្យាង្គ(០.៦៥)

-ចំណាប់ចូន

ចូនក្នុងល្ហះ - ៤ ១ ⟊ ៤ ៦

- ៦ ៦ ⟊ ៤ ៣ ⟊ ៤ ៤

ចូនធ្វងល្ហះ ៦ ៤ ១ ⟊ ៦ ៦ ៦(០.៦៥)

-ចង្វាក់៖ គេលើកជាក់សំឡេងលើព្យាង្គទី២ ចំពោះឃ្លាមាន៤ព្យាង្គ និងព្យាង្គទី២ ទី៤ ចំពោះឃ្លាមាន៦ព្យាង្គ។(០.៦៥)

-បរិយាកាស៖ កើតឡើងនៅសម័យអង្គរ គឺប្រើសម្រាប់ការឈ្លោះទាស់ទែងគ្នា ការមើលងាយ ការរិះគន់ កំប្លុកកំប្លែង ទូន្មានអប់រំ...។(០.៦៥)

៧.(ពិន្ទុ១០)

ក.សេចក្តីផ្តើម (ពិន្ទុ១)

-លំនាំបញ្ហា: បំផុសគំនិតទូទៅទាក់ទងនឹងប្រធានបទ។(០.៦៥)

-ចំណុលបញ្ហា: ស្របនឹងព័ន្ធោលមួយពោលថា-ធ្វើគុណច្រើនទទួលបានទោស-។(០.៦៥)

-ចំណោទបញ្ហា: តើព័ន្ធោលខាងលើសមហេតុផលដែរឬទេ?(០.៥០)

ខ.តួសេចក្តី (ពិន្ទុ៧)

-ឃ្លាក្បាប់សេចក្តី: ដើម្បីបកស្រាយបំភ្លឺគំនិតប្រធានខាងលើឱ្យបានស៊ីជម្រៅ ចាំបាច់យើង

ត្រូវយល់ន័យវាក្យតន្ទឹះជាមុនសិន។(០.៦៥)

-ពន្យល់ពាក្យតន្ទឹះ

ធ្វើគុណ: ធ្វើនូវអំពើល្អ ជួយទំនុកបម្រុង ជួយជ្រោមជ្រែង... (០.៦៥)

✓ ទោស: ខូចខាតបង់ ទុក្ខវេទនា វិនាស ទទួលផលអាក្រក់... (០.៦៥)

-ពន្យល់ន័យប្រធាន: ការធ្វើនូវអំពើល្អ ជួយទំនុកបម្រុង ជួយជ្រោមជ្រែងដល់នរណាមួយ តែងតែបានទទួលបានផលត្រឡប់មកវិញនូវការខូចខាតបង់ ទុក្ខវេទនា វិនាស ឬទទួលផលអាក្រក់ផ្សេងៗ។(០.៦៥)

-បកស្រាយប្រធាន

១មតិស្រប

-រឿងក្រពើរមិលគុណ(តាបសរកទេះជួយក្រពើ ចុងក្រោយក្រពើចង់ស៊ីតាវិញ) (១.០០)

-រឿងព្រះវេស្សន្តរ(ខិតខំបរិច្ចាគទាន ត្រូវគេស្តេចបរបង់ចេញពីនគរ) (១.០០)

-...

+សរុបមតិ: សរុបមកឃើញថាកាលការធ្វើនូវអំពើល្អ តែងតែទទួលបានមកវិញនូវផលសំបាក ទុក្ខសំបាក..។(០.៥០)

១មតិផ្ទុយ

-រឿងព្រះអាទិត្យថ្មីរះលើផែនដីថាស់(រដ្ឋមន្ត្រីវ័យក្មេងបានជួយសង្គមឱ្យផុតពីទុគ៌តជន រស់កនបានសេចក្តីសុខ និងក្លាយទៅជាកសិករគំរូ...) (១.០០)

-រឿងកូលាបប៉ែលិន(ហ្វូងតេនសម្បត្តិជួយចៅចិត្តឱ្យក្លាយទៅជាមនុស្សមានទីពឹង ចេះទទួលខុសត្រូវ ចេះជួយទុក្ខធុរៈអ្នកដទៃ...)(១.០០)

-...

+សរុបមតិ: សរុបមកឃើញថាកាលការធ្វើនូវអំពើល្អ តែងតែទទួលបានមកវិញនូវសេចក្តីសុខ និងធ្វើឱ្យអ្នកដទៃចាកផុតពីទុក្ខសំបាកផងដែរ។(០.៥០)

- មតិពិភាក្សា:ការធ្វើគុណតែងទទួលបានទោសបណ្តាលមកពីអ្នកធ្វើគុណទោះមិនយល់មិនចេះឆ្លាប់ទម្លាប់ មិនយល់កាលៈទេសៈ គឺធ្វើគុណតាមទម្លាប់តៗគ្នា តាមតែគំនិតខ្លួនឯងយល់ អាស្រ័យហេតុហ្នឹងហើយទើបបានជាចុងក្រោយទទួលនូវផលពិបាកទោះ។

(១.០០)

ក.សេចក្តីបញ្ជាប់ (ពិន្ទុ៧)

-ការយល់ឃើញប្រធានៈ ទស្សនៈប្រធានខាងលើមិនត្រឹមត្រូវទេ ជាទស្សនៈយល់តែខ្លួនឯង យល់តែមួយជ្រុង ធ្វើអ្វីមិនចេះគិតគូរ ជាពំនោលនេះមិនមានលក្ខណៈវិទ្យាសាស្ត្រទេ តែគោះជាយ៉ាងណាក៏បានជួយដាស់តឿនក្រើនរំឭកដល់មហាជន ឱ្យប្រុងប្រយ័ត្នក្នុងការជួយអាសាអ្នកដទៃ ចៀសវាងយ៉ាងណាកុំឱ្យជួយគេហើយមានទោសទៀត។(០.៥០)

-មតិផ្ទាល់ខ្លួនៈមនុស្សម្នាក់ៗមុនទីងធ្វើអ្វី ត្រូវរិះគិត ពិនិត្យពិចារណា សួរនាំឱ្យបានត្រប់ជ្រុងជ្រោយទើបប្រសើរ។(០.៥០)

ឃ.វចនាមជ (ពិន្ទុ៧)

ប្រឡងជ្រើសរើសគ្រូបង្រៀនអនុវិទ្យាល័យឧត្តម (បរិញ្ញា+១) ជំនាន់ទី១៩

សម័យប្រឡង ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៣

អត្រាកំណៅ ឯកទេសទី១ **មុខវិជ្ជា អក្សរសាស្ត្រខ្មែរ** **រយៈពេល១៨០នាទី**

ឈ្មោះ:.....លេខបន្ទប់.....លេខតុ.....ហត្ថលេខា.....

(ពិន្ទុ០.៧៥) ១. ព្យញ្ជនៈអឃោសៈ និងឃោសៈក្នុងភាសាបាលី និងមូលហេតុទាក់ទងអ-អក្នុងភាសាខ្មែរ មានការប្លែកគ្នាដូចជា៖

+សូរព្យញ្ជនៈភាសាបាលីគឺសញ្ញាព្យញ្ជនៈមួយ សម្គាល់សញ្ញាសូរមួយ ដាច់ដោយឡែកពីគ្នា។ ឧ: ក [ka] គ [ga]... (០.២៥)


ចំណែកភាសាខ្មែរ ឃើញថាសញ្ញាព្យញ្ជនៈពីរ តត់សញ្ញាសូរតែមួយ។ ឧ: កគ [k]... (០.២៥)


+ព្យញ្ជនៈខ្មែរចែកចេញជាព្យញ្ជនៈទាក់អ-អដាច់ពីគ្នា គឺទាក់អ មាន(២៨តួ)៖ ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ អ ឯទាក់អ៊ មាន(២៦តួ)៖ អ ឣ ឤ ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឲ ឳ។ ចំណែកតួព្យញ្ជនៈទាក់អឃោសៈមាន(១១តួ)៖ ក ខ ច ឆ ដ ឋ ត ថ ប ផ ស ទាក់ឃោសៈមាន(២១តួ)៖ គ ឃ ង ជ ឈ ញ ឌ ឍ ណ ទ ធ ន ព ភ ម យ រ ល វ ហ ឡ។(០.២៥)

(ពិន្ទុ០.៧៥) ២.ដែលហៅថាល្បះជ្បំ គឺជាការបន្សំរវាងល្បះ តាប់គ្នាដោយសញ្ញាមណ្ឌាប់ ឬ ណ្ឌាប់ឃ្លា ដែលបង្កើតបានឃ្លាច្បង និងឃ្លារណម។ ជាទូទៅ ល្បះជ្បំមានទម្រង់បី គឺល្បះជ្បំប្រើឃ្លាគុណនាម ប្រើឃ្លានាម និងប្រើឃ្លាទេសកាល។ (០.២៥)


បង្កើតល្បះទៅតាមទម្រង់ល្បះជ្បំនីមួយៗ និងគូសមែកធាងផង៖

១.ល្បះជ្បំប្រើឃ្លាគុណនាម: អ្នកដើរដែលពាក់អាវពណ៌សនោះជាគ្រូបង្រៀនៗ។





៣. ល្បះជ្បុំប្រើឃ្លាទេសកាល: និស្សិតរកមើលឈ្មោះដើម្បីគេស្គាល់បន្ទប់ប្រឡង។



បង្កើតបានកែល្បះ (០.២៥) គូសមែកធាង(០.២៥)

(ពិន្ទុ០.៧៥) ៣.កំណាល្បះខ្មែរ គេប្រើសញ្ញាថ្ងូចជា៖

-សញ្ញាពន្យល់មាន៖ សញ្ញាចូន ⊢ សញ្ញាថ្ងូន ⊣ សញ្ញារណ្តំ ⊢

ឧ: ល្បាង្គទី៧ ឃ្លាទី១ ⊢ ល្បាង្គទី៨ឃ្លាទី២ (០.២៥)

-សញ្ញាគំទ្ធសភាងមាន៖ សញ្ញាចូន ⌐ ថ្ងូន ⌐ រណ្តំ ⌒

ឧ: ១២៣៤៥៦៧ ⌐ ⌐ ១២៣៤៥៦៧ (០.២៥)

-សញ្ញាពងត្រី(ចូនកាលប្រើលេខ)គេប្រើសម្រាប់សម្គាល់ល្បាង្គមួយនៅក្នុងឃ្លាល្បះ។

ឧ:OOOOOOO OOOOOOO

OOOOOOO OOOOOOO។(០.២៥)

-ចំណាប់ចូនបទពាក្យជ្រាំបី៖

ចូនក្នុងល្បះ - ៨១១ ⫤ ៥២១

- ៨២១ ⫤ ៨៣១ ⫤ ៥៨១

ចូនឆ្លងល្បះ ៨៨១ ⫤ ៨២២

-ចំណាប់ចូនបទបញ្ចាវដ្ត៖

ចូនក្នុងល្បះ - ៨១១ ⫤ ៨២១

- ៨២១ ⫤ ៨៣១ ⫤ ៨៨១

ចូនឆ្លងល្បះ ៨៨១ ⫤ ៨១២ (០.២៥)

+ ចង្វាក់

-ចង្វាក់បទពាក្យជ្រាំបី គេលើកដាក់សំឡេងលើល្បាង្គទី៣ និងទី៥គ្រប់ឃ្លា។

-ចង្វាក់បទបញ្ចាវដ្ត គេលើកដាក់សំឡេងលើល្បាង្គទី២ ទី៤ និងទី៦គ្រប់ឃ្លា។(

+ បរិយាកាស


-បរិយាកាសបទពាក្យជ្រាំបីប្រើបានគ្រប់បរិយាកាស ឬគ្រប់សម័យកាល។

-បរិយាកាសបទបញ្ចាវដ្ត ប្រើសម្រាប់រៀបរាប់ពីស្នាព្រះហស្ត ឬវីរភាពនៃស្តេច

ណាមួយ។ (០.២៥)


(ពិន្ទុ១.៥០) ៥.តែងអត្ថបទកំណាព្យខ្មែរជាបទបញ្ចាវដ្តឱ្យបានជ្រាំវត្ត ស្តីពី «សាមគ្គីធម៌»។

ឧទាហរណ៍



១.ooooooooo ooooooooo

ooooooooo ooooooooo។



២.ooooooooo ooooooooo

ooooooooo ooooooooo។

-សរសេរបានជ្រាំល្បះ(០.៥០)

-ចំណាប់ចូនក្នុងល្បះ និងឆ្លងល្បះត្រឹមត្រូវ(០.៥០)

-អត្ថន័យ(០.៥០)

.អំពើល្អយកតម្រាប់តាម(០.៦៥)

-គោរពដំបូន្មានល្អ

ទាងចាស្តាប់បង្គាប់ម្តាយ(ធ្វើតាមយាយទូន...)

ប៊ុនធឿនស្តាប់បង្គាប់ឪពុក(ទៅរៀនបន្តទៀត...)

-គោរពប្រពៃណីជាកូនខ្មែរបានល្អ...

-អត់ធ្មត់គ្រប់ការងារ....

-ភក្តីចំពោះស្នេហា។ (ក្រៅពីចំណុចបានពិន្ទុពេញ)

.អំពើអាក្រក់កុំយកតម្រាប់តាម(០.៦៥)

.បំពេញតែបំណងខ្លួនឯង (ក្រៅពីចំណុចបានពិន្ទុពេញ)

យាយទូនឱ្យកូនធ្វើតាមតែខ្លួនគិតថាត្រូវ...

ឪពុកប៊ុនធឿនគិតធ្វើការកេស្តីតែម្នាក់ឯង...

មិនគ្រោកឈឺកេស្តីចំពោះស្នេហាខ្លួន...។

(ពិន្ទុ៥) ៧.ប្រធាន

មតិអ្នកខ្លះយល់ថា "យល់ញាតិឃ្លាតច្បាប់ " ឯអ្នកខ្លះទៀតយល់ថា "យល់ច្បាប់ស្លាប់ញាតិ "។ តើអ្នកយល់យ៉ាងណាដែរ? ចូរលើកឧទាហរណ៍ក្នុងសង្គមមនុស្ស និងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

សេចក្តីអត្ថាធិប្បាយក្បៀង

ក.សេចក្តីផ្តើម

-សំនាំបញ្ហា: និយាយទាក់ទងនឹងប្រធានបទ

(០.៥០) -ចំណុលបញ្ហា: មតិអ្នកខ្លះយល់ថា "យល់ញាតិឃ្លាតច្បាប់ " ឯអ្នកខ្លះទៀតយល់ថា "យល់ច្បាប់ ស្លាប់ញាតិ "។

-ចំណោទបញ្ហា:តើមតិខាងលើមួយណាខុស មួយណាត្រូវ?

ខ.ត្រួសេចក្តី

(០.២៥) -ឃ្លាភ្ជាប់សេចក្តី

-ពន្យល់ពាក្យគន្លឹះ

ច្បាប់:សេចក្តីបញ្ញត្តិសម្រាប់ឱ្យអ្នកនគរប្រតិបត្តិតាម ឬវិន័យ ក្រឹត្យក្រម ក្បួនប្រៀបមនុ
ឱ្យប្រព្រឹត្តល្អ។

បងប្អូន ឬសាច់ឈាមសាលោហិតដែលជាប់ខ្សែស្រឡាយគ្នា អ្នកជំពាក់ជំពិនគប់អា
បានប្រព្រឹត្តខុស យើងអ្នកកាន់ច្បាប់មិនយកទោសគៃ ដោយអាងថាគ្នាឯង នោះវិន័យបញ្ញ
និងលែងមានប្រសិទ្ធភាព តែបើយើងយកច្បាប់មកអនុវត្តដោយគ្មានត្រែងត្រម៉ត្រូវ នោះក៏ជាបេ
ឱ្យញាតិមិត្តបងប្អូនវិនាសព្រាត់ប្រាសទៅវិញ។

-បកស្រាយប្រធាន

មតិទី១

(០.៥០) ក្នុងសង្គមមនុស្សជាក់ស្តែង ទីកន្លែងណាមិនអនុវត្តច្បាប់ បង្កភាពអនាធិបតេយ
ដូចជាតាមហាងលក់ថ្នាំ តាមសាលារៀន តាមបន្ទប់រវេទ្យ ស្ថាប័ននានា ពេលដែលមាន
មនុស្សច្រើន គ្មានច្បាប់ទម្លាប់ វានឹងរញ៉ៃរញ៉ៃគ្មានសណ្តាប់ធ្នាប់...។

(៥.៥០) ក្នុងអក្សរសិល្ប៍រឿងថៅកែចិត្តចោរ នគរបាលមិនចាប់ថៅកែ ដោយពេលនោះ
ថៅកែបានឱ្យបាម្នាយនគរបាល ធ្វើឱ្យកម្មករបះចោរ មតិអ្នកអានមិនសប្បាយចិត្ត...។
(សិស្សអាចលើកឧទាហរណ៍ផ្សេងៗទៀតបានឱ្យតែត្រូវ)

សរុបមតិៈការយោគយល់គ្នាឯងដែលខុសច្បាប់មិនយកទោសគៃដាក់ពិន័យ ន
ការរស់នៅច្របូកច្របល់គ្មានសណ្តាប់ធ្នាប់។

មតិទី២

(០.៥០) ក្នុងសង្គមមនុស្សជាក់ស្តែង ទីកន្លែងណាអនុវត្តច្បាប់ទម្លាប់បានត្រឹមត្រូវ ទីនោះ
ត្រែងត្រែមនុស្សខ្លះខ្នាក់ខ្នាយនៃវាស ជាក់ស្តែងតាមហាងលក់ថ្នាំ តាមសាលារៀន កុមម
រវេទ្យ ស្ថាប័ននានា ដែលអនុវត្តច្បាប់ទម្លាប់ត្រឹមត្រូវ មនុស្សមួយចំនួនត្រែងនៃវាស...។

(០.៥០) ក្នុងអក្សរសិល្ប៍រឿងថៅកែចិត្តចោរ ទាហ៊ានបានប្រព្រឹត្តខុសច្បាប់សង្គម ដោយបើ
ឱ្យានបុកគ្នាដោយចេតនា មានស្លាប់មនុស្ស ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់...។

សរុបមតិ អនុវត្តច្បាប់ត្រឹមត្រូវនាំឱ្យមានអ្នកខ្លះត្រូវជាប់ទោស បាត់បង់ ខូចខាត

(០.៥០) -មតិពិភាក្សា

មតិទីពីរមិនត្រឹមត្រូវទេ ច្បាប់បង្កើតមកសម្រាប់គ្រប់គ្រងសង្គមឱ្យមានសុខសុវត្ថិភាព
ភាពសុខសាន្ត រឿងអ្វីទៅជាការស៊ីម្ហាប់ញាតិទៅវិញ។ការប្រព្រឹត្តខុស ត្រូវទទួលខុសត្រូវចំពោះ
មុខច្បាប់ជាការត្រឹមត្រូវ។

គ.សេចក្តីបញ្ចប់.

(០.២៥) -ឯយកម្លៃប្រជាន: អប់រំមនុស្សឱ្យគោរពច្បាប់ទម្លាប់ ដើម្បីរស់នៅជួបជុំគ្នាបានសេចក្តីសុខ

(០.២៥) -មតិផ្តាល់ខ្លួន: ស្វែងយល់ពីច្បាប់ នាំគ្នាគោរពច្បាប់ ការរស់នៅសុខសាន្ត។

ឃ.រចនាបថ(ប.៥០)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
វិទ្យាស្ថានជាតិអប់រំ

ប្រឡងជ្រើសរើសគ្រូបង្រៀនភូមិគន្ធថ្នាក់ឧត្តម (ឆមាស + ១) ជំនាន់ទី២០
សម័យប្រឡង ៖ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៤
វិញ្ញាសា ៖ អក្សរសាស្ត្រខ្មែរ រយៈពេល ៖ ១៨០នាទី ពិន្ទុ ៖ ២០/២០

អត្ថាធិប្បាយ

(១,00ពិន្ទុ) ១. ក. ទ្ឋានកថា គឺជាឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងអត្ថបទ (ភាគច្រើនជាពាក្យកាព្យ) សម្រាប់អប់រំណែនាំជនានុជន កុលបុត្រ កុលធីតា ឱ្យដើរក្នុងផ្លូវល្អ ខានសីលធម៌ គុណធម៌ ក្នុងដីវភាពរស់នៅ។
ឧទាហរណ៍ : ច្បាប់ពាក្យចាស់ ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់ក្រម ច្បាប់កេរ្តិ៍តា ច្បាប់រាជនីតិ ច្បាប់ទ្ឋានខ្លួន ច្បាប់ប្រដៅជនប្រុសស្រី ច្បាប់ប្រដៅកូនចៅ...។
ខ. អត្ថប្រយោជន៍នៃទ្ឋានកថាចំពោះស្នាដៃអក្សរសិល្ប៍ ៖
. ជាមធ្យោបាយដែលអាចឱ្យកវី អ្នកនិពន្ធ ប្រើប្រាស់ទ្រឹស្តីវិចិត្រសិល្ប៍ទៅក្នុងស្នាដៃអក្សរសិល្ប៍ដូចជា ថ្នៃប្រាប់ដោយត្រង់ និងថ្នៃប្រៀបធៀបឬឧបមានវិធី (ច្បាប់ពាក្យចាស់.. ដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ ឱ្យលុះតាមឱវាទទ្ឋានរបស់កវី អ្នកនិពន្ធ។
. ជាវិធីបង្ហាញនូវលក្ខណៈសម្បូរបែបនៃពុទ្ធិ អំពីការប្រកបរបរចិញ្ចឹមជីវិតដោយធ្វើកសិកម្ម សិប្បកម្មជាដើម (ច្បាប់ប្រុស ច្បាប់ស្រី...) ពិសេសវិធីប្រតិបត្តិក្នុងជីវភាពរស់នៅ ដើម្បីផ្តល់នូវការអប់រំណែនាំជនានុជន កុលបុត្រ កុលធីតា ឱ្យដើរក្នុងផ្លូវល្អ មានសីលធម៌ គុណធម៌។
. ជាតម្លៃដែលរលឹងឡើងនៅក្នុងស្នាដៃអក្សរសិល្ប៍ ដូចជា កុសលសេ តថរស តាឲ្យសេ សោភណរស ទស្សនីយសេ... ដែលស្តែងឡើងតាមរយៈការឆ្លុះបញ្ចាំងនូវសច្ចភាពសង្គមគ្រប់សម័យកាល រួមមាន ការគ្រប់គ្រង និន្នាការនយោបាយ ទស្សនៈ ផ្នត់គំនិត ជីវភាពរស់នៅជំនឿ ទំនៀមទម្លាប់ប្រពៃណី សាសនា...។

(១,00ពិន្ទុ) ២. លក្ខណៈជាតិនៅក្នុងរឿងទុំទាវ ស្តែងឡើងនៅក្នុងផ្នែកអត្ថន័យ អត្ថរូប និងអត្ថរស។
+ ផ្នែកអត្ថន័យ ៖
- របៀបរបបគ្រប់គ្រងនាសម័យលង្វែក
. សង្គមខ្មែរត្រូវបានគ្រប់គ្រងដោយស្តេចដែនដី ស្តេចក្រាញ់។
. សង្គមខ្មែរប្រកាន់យករបបមាតាធិបតេយ្យ។
- បញ្ហាស្នេហា
. ភក្តីភាព ៖ សង្គមខ្មែរចាត់ទុកភក្តីភាពជាប្រពៃណីជាតិរបស់ខ្មែរ មានតម្លៃលើសអាយុជីវិតមនុស្សទៅទៀត។ ទាវសុខចិត្តធ្វើអគ្គឃាតដើម្បីរក្សាភក្តីភាពចំពោះទុំ។ ទុំទាវហ៊ានប្រឆាំងនឹងអ្វីៗទាំងអស់ដើម្បីរក្សាភក្តីភាព។

. មិនទុំមុនស្រគាល ៖ មាតាបិតាខ្មែរតែងហាមប្រាមកូនចៅមិនឱ្យ
សេចក្តីស្នេហាផ្តេសផ្តាសឡើយ ព្រោះវាធ្វើឱ្យអាប់ឱនកិត្តិយសវង្សត្រកូល។

- ជំនឿ

. ប្រជាពស្ត្រីខ្មែរសម័យលង្វែក~~ដូចជាសម័យមុនៗ~~ មានជំនឿទៅលើ
កម្មផលតាមព្រះពុទ្ធសាសនា។

. ប្រជាពស្ត្រីខ្មែរនៅនិយមជឿលើការទស្សន៍ទាយពីជោគវាសនារបស់ខ្លួន។

. គេនិយមជឿលើមន្តអាគមិគាថា (ទុំស្ងួតមន្តអាគម សារិកាលិនថោង)

- ទំនៀមទម្លាប់ប្រពៃណី

. ការទុកដាក់កូនចៅឱ្យមានគ្រួសារ ៖ សង្គមខ្មែរឱ្យសិទ្ធិសេរីភាពទៅ
មាតា។ ម្តាយខ្មែរភាគច្រើនប្រកាន់យកច្បាប់គ្រួសារ -ទំមិនធំជាងនាឡិ-។

. ពិធីចូលម្លប់ ៖ សង្គមខ្មែរនាសម័យលង្វែកតម្រូវឱ្យកូនស្រីដែលមាន
វ័យគ្រប់ការចូលម្លប់រដើម្បីរៀនវិជ្ជាមេផ្ទះ។

. ពិធីរៀបអាពាហ៍ពិពាហ៍ ៖ គេតម្រូវឱ្យកូនប្រុសចូលស្តីដណ្តឹងកូនស្រី
ដោយមានមេបា ចៅមហា ហើយពិធីមង្គលការត្រូវប្រព្រឹត្តទៅនៅផ្ទះខាង
កូនស្រី។

- សាសនា និងតួនាទីវត្តអារាមក្នុងសង្គមខ្មែរ

. វត្តអារាមមិនគ្រាន់តែមានតួនាទីសំខាន់ក្នុងផ្លូវសាសនាប៉ុណ្ណោះទេ ថែម
ទាំងបានបណ្តុះបណ្តាលពុទ្ធិដល់មហាជនទៀតផង។

. ព្រះសង្ឃខ្មែរមិនត្រឹមតែសិក្សាទ្រឹស្តីផ្នែកសាសនា ថែមទាំងរៀនអក្សរ
លេខនព្វន្ត សិប្បកម្ម សិល្បៈ តន្ត្រី (តោក ស្នូត្រ ឆ្នុំស្គឹក ឆ្នុំប៉ី) ...។

. ប្រជាពស្ត្រីខ្មែរនិយមឱ្យកូនប្រុសទៅឫសរៀន ហើយពេលសឹកមកវិញ
គេឱ្យនាមថា~អន្ទិត~។

. ប្រជាពស្ត្រីខ្មែរចូលចិត្តស្តាប់លោកស្នូត្រ និងទេសនា។

- ចរិតលក្ខណៈរបស់តួអង្គ

. រឿងទុំទាវបានបង្ហាញនូវចរិតលក្ខណៈរបស់តួអង្គសំខាន់ៗ ដែលសម្តែង
ចេញតាមរយៈ សកម្មភាព ដំណើរចិត្តគំនិត និងសតិអារម្មណ៍ពិតៗរបស់
ប្រជាពស្ត្រីខ្មែរ។ ទុំតំណាងឱ្យព្រះសង្ឃខ្មែរដែលមានពុទ្ធិខាងអក្សរសាស្ត្រ
និងវិជ្ជាជីវៈដែលបណ្តុះបណ្តាលតាមវត្តអារាមនាសម័យលង្វែក។ នាសម័យ
នោះ កិក្ខុសង្ឃត្រូវបានអនុញ្ញាតឱ្យទៅធ្វើជំនួញដោយសេរី។

. តួអង្គទុំទាវតំណាងឱ្យយុវជននាសម័យលង្វែកដែលចង់បានសេរីភាព
ការជ្រើសរើសគ្រួសារ។

. តួអង្គម្តាយទាវតំណាងឱ្យម្តាយខ្មែរនាសម័យលង្វែកដែលនិយមប្រើ
អំណាចផ្តាច់ការលើកូនចៅ ពិសេសក្នុងបញ្ហារៀបចំគូអនាគត។

. តួអង្គអ្នកនំតំណាងឱ្យចៅហ្វាយស្រុកនាសម័យលង្វែកដែលប្រើអំណាច
ផ្តាច់ការចំពោះប្រជាពស្ត្រ។

2

- ជីវភាពនៃសង្គមខ្មែរ

. ឈ្មោះតូអង្គ ៖ ជាឈ្មោះខ្មែរសុទ្ធសាធ កើតនិងរស់នៅលើទឹកដីខ្មែរ ដូច
ទុំ ទាវ ពេជ្រ នោ អាជូន ម៉ឺនឆ្ងន។

. ទីតន្លែង ៖ ជាភូមិ ស្រុក ខេត្ត នៅក្នុងភូមិសាស្ត្ររបស់មាតុភូមិកម្ពុជា (ច
ត្បូងឃ្មុំ ពោធិ៍ជើងខាល វត្តវិហារធំ)

. ចម្ម៉ជាតិដែលមានពិតនៅលើទឹកដីខ្មែរ (ឯលវែង ផ្ការក្រែង ស្មៅត្រកៀ
ត្រកួន ត្របែកក្រៃ...)។

. ជីវភាពនិងសម្ភារៈ ៖ បង្ហាញពីជីវភាពប្រជាពស្ត្រខ្មែរស្រុកស្រែចម្ក
ឧបករណ៍ប្រើប្រាស់ក្នុងជីវភាពរស់នៅ (គោក ដាំកប្បាស ចិញ្ចឹមដង្កូវនាង.

. មធ្យោបាយធ្វើដំណើរ ៖ ផ្លូវទឹកប្រើទូក ផ្លូវគោកប្រើរទេះគោជាដើម។

+ ផ្នែកអត្ថបទ ៖ ប្រើប្រាស់ភាសាជាតិ និងទម្រង់កំណាព្យខ្មែរសម្រាប់តាក់តែងស្នាដៃ។

+ ផ្នែកកត្តរស ៖ ការ្យរស ប្រលោមរស តថរស ទារុណរស ទិស្សនីយរស សោកាវេរ
សុន្ទររស កុសលរស...។

(១,៥០ពិន្ទុ) ៣. នៅក្នុងភាសាខ្មែរ គេចែកសព្ទនាមជា៥ ដូចជា សព្ទនាមបុរិស: សព្ទនាមឈ្ម
សព្ទនាមចង្កៀល សព្ទនាមសំណួរ និងសព្ទនាមមិនច្បាស់។

- សព្ទនាមបុរិស: ៖ គឺជាសព្ទនាមដែលតំណាងបុរិស:ទាំង៣
ក្នុងភាសាខ្មែរសព្ទនាមបុរិស:មាន ៖

. បុរិស:ទី១ ៖ ខ្ញុំ អញ យើង...។

. បុរិស:ទី២ ៖ ឯង អ្នក...។

. បុរិស:ទី៣ ៖ វា គាត់ នាង...។

- សព្ទនាមឈ្មោះ ៖ គឺជាសព្ទនាមសម្រាប់ជំនួសនាម ឬកន្សោមនាមដើម្បីបង្កើតល្ប
រណប។ នៅក្នុងភាសាខ្មែរ សព្ទនាមឈ្មោះមានតែមួយគត់ដែល

ឧទាហរណ៍ ៖ ខ្ញុំបានជួបកុមារម្នាក់ដែលរៀនឲ្យកែជាងគេក្នុងសាលារៀននេះ។

- សព្ទនាមចង្កៀល ៖ គឺជាសព្ទនាមដែលប្រើសម្រាប់ចង្កៀលបង្ហាញ មនុស្ស សត្វ ឬ វត្ថុ
ឱ្យឃើញច្បាស់លាស់ ថានៅទីជិត ឬទីឆ្ងាយ ពីអ្នកនិយាយ។ ពាក្យ នេះ នោះ...
ជាសព្ទនាមចង្កៀល។

ឧទាហរណ៍ ៖ នេះជាសៀវភៅរបស់ខ្ញុំ នោះជាសៀវភៅរបស់ឯង។

- សព្ទនាមសំណួរ ៖ គឺជាសព្ទនាមប្រើសម្រាប់សួរកប្រធាន ឬសួរកកម្មរង / កម្មបទ
របស់កិរិយាសព្ទ។ សព្ទនាមសំណួរមានដូចជា នរណា អ្វី នរណាម្នាក់ អ្វីមួយ...។

ឧទាហរណ៍ ៖ - នរណាដើរកាត់ទីនេះ? (សួរកប្រធាន)

- ឯងនិយាយអំពីអ្វី? (សួរកកម្មបទមិនផ្ទាល់)

- គាត់ទិញអ្វី? (សួរកកម្មបទផ្ទាល់)

- សព្វនាមមិនច្បាស់ ៖ គឺជាសព្វនាមដែលគេប្រើជំនួសនាម ឬកន្សោមនាម ដែលស្ថិ
លក្ខណៈទូទៅ ដោយមិនបញ្ជាក់ច្បាស់ចំពោះនាម ឬកន្សោមនាមណាមួយឡើយ។ ពា
·នណាម្នាក់ អ្នកណាល់គ្នា នរណាមួយ...·ជាសព្វនាមមិនច្បាស់។
ឧទាហរណ៍ ៖ អ្នកណាល់គ្នាត្រូវទៅធ្វើការឱ្យទាន់ពេលវេលា។

(២,០០ពិន្ទុ) ៤. ក. ពាក្យ គឺជាស្វរូបនៃសទ្ទ បង្កើតបានមួយបន្សាយសំឡេង ពីរបន្សាយសំឡេង ឬបន្សាយសំឡេង-ហើយមានន័យគ្រប់គ្រាន់ស្តាប់បាន។

ខ. មុខងាររបស់ពាក្យ

១. ប្រធាន ៖ កន្សោមនាម ឬកន្សោមនាមប្រធាន គឺជាកន្សោមនាមនៅខាងក្
កន្សោមកិរិយាដែលជាអ្នកធ្វើអំពើ ឬប្រកបសភាពលក្ខណៈណាមួយក្នុងល្បះ។
ឧ. កសិករម្នាក់បររទេះគោ។ កន្សោមនាម ·កសិករម្នាក់· ជាកន្សោមប្រធាន។

២. កម្មបទ ៖ កម្មបទចែកចេញជាពីរ គឺកម្មបទថ្នាល់ និងកម្មបទមិនថ្នាល់។

- កម្មបទថ្នាល់ គឺជាកន្សោមនាមដែលជាធាតុរបស់កន្សោមកិរិយា នៅជាប់ខាងស្តាំ
កិរិយា ស្រាប់បញ្ជាប់នយសេចក្តីរបស់កិរិយាឱ្យបានច្បាស់លាស់។
(ជាកន្សោមអចលិត)

ឧ. កសិកររែកជីធម្មជាតិ។ កន្សោមនាម ·ជីធម្មជាតិ· ជាកម្មបទថ្នាល់។

- កម្មបទមិនថ្នាល់
គឺជាកន្សោមនាមមានឆ្នាក់ដែលជាធាតុសំណង់របស់កន្សោមកិរិយាសម្រាប់បញ្ជាប់
នយសេចក្តីរបស់កិរិយាឱ្យបានច្បាស់លាស់។ (ជាកន្សោមអចលិត)

ឧ. សំសិក្សាអំពីវេយ្យាករណ៍។ កន្សោមនាមមានឆ្នាក់ ·អំពីវេយ្យាករណ៍· ជាកម្មបទ
មិនថ្នាល់។

៣ គុណប្រធាន ៖ គឺជាកន្សោមនាមដែលជាធាតុសំណង់របស់កន្សោមកិរិយា
ស្រាប់បង្ហាញឯកលក្ខណភាពនៃប្រធាន ឬសភាពលក្ខណៈរបស់ប្រធាន។
ឧ. សុខជាសិស្សវិទ្យាល័យ។ កន្សោមនាម ·សិស្សវិទ្យាល័យ· ជាគុណប្រធាន។

៤. គុណបទ ៖ គឺជាគុណនាមប្រក្រតី ឬអាចជាឃ្លាគុណនាមដែលជាធាតុសំណង់
របស់កន្សោមនាមស្រាប់ចង្អុលបង្ហាញសភាពលក្ខណៈ ឬគុណភាពនៃនាម។
ឧ. ផ្ទះថ្មីសង់ក្បែរមាត់ស្ទឹង។ ពាក្យ ·ថ្មី· ជាគុណបទ។

៥. ឧបបទ ៖ គឺជាកន្សោមពាក្យ (នាម កន្សោមនាម ឬឃ្លាគុណនាម) ដែលជាធាត
សំណង់របស់កន្សោមនាម សម្រាប់បញ្ជាក់លក្ខណៈឱ្យនាម ឬកន្សោមនាមបង្កើ
ឱ្យមានន័យច្បាស់លាស់។
ឧ. កម្ពុជា មាតុភូមិខ្ញុំសម្បូរសម្បត្តិធម្មជាតិ។ កន្សោមពាក្យ ·មាតុភូមិខ្ញុំ· ជាឧបបទ។

៦. កម្មបំពេញបទ ៖ គឺជាកន្សោមមានឆ្នាក់ ដែលជាធាតុសំណង់របស់កន្សោម
សម្រាប់បង្ហាញឱ្យជាក់លាក់ និងកម្រិតស្រិះដននីយរបស់នាមដោយចង្អុលទ្វ
កម្មសិទ្ធិ (ប្រើឆ្នាក់ -នៃ- និង -របស់-)

ឧ. រាជធានីនៃព្រះរាជាណាចក្រកម្ពុជាសម្បូរសម្បត្តិធម្មជាតិ។ កន្សោម
-នៃព្រះរាជាណាចក្រកម្ពុជា- ជាកម្មបំពេញបទ។

៧. កម្មទេសកាល ៖ គឺជាកន្សោមនាម កន្សោមមានឆ្នាក់ ឬគុណកិរិយា សប្
ចង្អុលបង្ហាញបញ្ជាក់ទីកន្លែង កាល បំណង បែបបទ ហេតុជាដើម របស់អ
សកាពដែលសម្តែងឡើងដោយកិរិយាសព្ទ។

ឧ. - ឲ្យសៅ បានទទួលផលស្រូវច្រើនពីស្រែជម្រៅ។ កន្សោមមាន
-ពីស្រែជម្រៅ- មានមុខងារជាកម្មទេសកាលបញ្ជាក់ពីទីកន្លែង។

- ឆ្នាំទៅ ឲ្យសៅបានទទួលផលស្រូវច្រើន។ កន្សោមនាម -ឆ្នាំទៅ- មានមុខងា
កម្មទេសកាលបញ្ជាក់ពីកាល។

- ឲ្យសៅបានយកចិត្តទុកដាក់ថែរក្សាសន្ទូង ដើម្បីផលស្រូវល្អ។ កន្សោមមានឆ្
-ដើម្បីផលស្រូវល្អ- មានមុខងារជាកម្មទេសកាលបញ្ជាក់ពីបំណង។

- ឲ្យសៅថែរក្សាសន្ទូងដោយយកចិត្តទុកដាក់។ កន្សោមមានឆ្នាក់ -ដោយយក
ទុកដាក់- មានមុខងារជាកម្មទេសកាលបំណែប។

- ឲ្យសៅបានផលស្រូវច្រើនដោយសារសន្ទូងល្អ។ កន្សោមមានឆ្
-ដោយសារសន្ទូងល្អ- មានមុខងារជាកម្មទេសកាលបញ្ជាក់ពីហេតុ។

(១,០០ពិន្ទុ) ៥. ភាពខុសគ្នារវាងឧបមានរូបាមួយ និងរូបាបិយាមួយ

. ភាពខុសគ្នាគឺស្ថិតនៅត្រង់ រូបាបិយាមួយមានទំហំវែងជាងឧបមានរូបាមួយ។

. រូបាបិយាមួយ ច្រើនក្លាយមកអំពីឧបមានរូបាមួយ ឬឧបមានន័យរូបាមួយ។

. ឧបមានរូបាមួយ គឺជារូបាមួយក្នុងអត្ថបទកំណាព្យ អត្ថបទភាក្យាយ ដែលកើតឡើ
តាមរយៈពាក្យពេចន៍ ឃ្លាប្រយោគ រំលេចឱ្យឃើញនូវការប្រៀបធៀបពាក្យ។ កវីនិព
ប្រើប្រាស់ពាក្យ ៖ ដូច ដូចជា រូបហាន ហាក់ ហាក់ដូចជា ធៀបនឹង ប្រៀបធៀបនឹង...។

ឧទាហរណ៍ : ពាលស្រែ និងព្រៃភ្នំដែលពោរពេញទៅដោយទឹកចិត្តដ៏ស្មោះត្រ
ដូចទឹកចិត្តរបស់បុព្វបុរសខ្មែរសម័យអង្គរ។

. រូបាបិយាមួយ គឺជារូបាមួយសិល្បៈមួយប្រភេទដែលមាននៅក្នុងវគ្គនីមួយៗ ឬនៅក្នុ
អត្ថបទទាំងមូល។ រូបាបិយាមួយ ច្រើនក្លាយមកអំពីឧបមានរូបាមួយ ឬឧបមានន័យ
រូបាមួយ។ ភាពខុសគ្នាគឺស្ថិតនៅត្រង់ រូបាបិយាមួយមានទំហំវែងជាងប៉ុណ្ណោះ។

ឧទាហរណ៍ : ឧបមានរូបាមួយដែលក្លាយទៅជារូបាបិយាមួយ
ក្តីបបុិចលេចពីទង្ហា ខ្ចីចាស់ជលា ស្រគាលហើយខ្ញុំទៀងហោង។
ឬណាឆ្នាក់ចុះចាកលែងទង ដូចកំណើតសត្វជង អន្លោលអន្ទាក់ភពស្ថាន។

(០,៥០ពិន្ទុ) ៦. តែងកំណាព្យបទបញ្ចាវត្តឱ្យបានពីរឈ្នះស្តីអំពី «ភាពស្មោះត្រង់»។

១ ២ ៣ ៤ ៥ ៦ ៧ ៨

១២៣៤៥៦៧៨	១២៣៤៥៦៧៨។
១២៣៤៥៦៧៨	១២៣៤៥៦៧៨
១២៣៤៥៦៧៨	១២៣៤៥៦៧៨។

(៣,០០ពិន្ទុ) ៧. សេចក្តីអត្ថាធិប្បាយ

I. ផ្តើមសេចក្តី .

១. លំនាំបញ្ហា : បំផុសគំនិតទៅទាក់ទងនឹងប្រធាន។

២. ចំណុលបញ្ហា : ហេតុនេះហើយទើបមានមតិមួយលើកឡើងថា «ស្វន សម ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ជាមនុស្សពោរពេញដោយគុណសម្បត្តិ»។

៣. ចំណោទបញ្ហា :

- តើចំណុចណាខ្លះដែលបញ្ជាក់ថា ស្វន សម ជាមនុស្សពោរពេញដោយគុណសម្បត្តិ?
- តើមតិខាងលើមានអត្ថន័យដូចម្តេចខ្លះ?

II. តួសេចក្តី

១. ឃ្លាភ្ជាប់សេចក្តី : មុននឹងឈានទៅដល់ការបកស្រាយប្រធានខាងលើ យើងគប្បីយល់អត្ថន័យនៃពាក្យគន្លឹះជាមុនសិន។

២. ពន្យល់ពាក្យគន្លឹះ :

- គុណសម្បត្តិ : ការបរិបូណ៌ដោយសេចក្តីល្អ។

៣. ពន្យល់ន័យប្រធាន : ស្វន សម ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ជាមនុស្សដែលបរិបូណ៌ដោយសេចក្តីល្អ។

៤. បកស្រាយប្រធាន

ស្វន សម ជាមនុស្សដែលបរិបូណ៌ដោយសេចក្តីល្អ ដូចជា :

+

+

+

៥. សរុបមតិ : ស្ងួន សម ពិតជាមនុស្សដែលបរិបូណ៌ដោយសេចក្តីល្អ។

III. បញ្ចាប់សេចក្តី

១. វាយតម្លៃប្រធាន : ទស្សនៈប្រធានមានតម្លៃជ្រាលជ្រៅដោយបានអប់រំមនុស្ស ប្រព្រឹត្តតែអំពើល្អ សុចរិត ស្មោះត្រង់...។

២. មតិផ្ទាល់ខ្លួន : ខិតខំសាងអំពើល្អ សុចរិត ជាពលរដ្ឋល្អសម្រាប់សង្គមជាតិ។

IV. រចនាបថ

. អក្សរស្អាត

. សរសេរមានរបៀប (មានផ្តើមសេចក្តី ឫសេចក្តី បញ្ចាប់សេចក្តី ចូលដើមបន្ទាប់ ចុះបន្ទាត់ មានសញ្ញាខណ្ឌ សញ្ញាសួរ ដកឃ្លា...)

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨

អ្នកកត់ត្រា.

ទេស ហាវ

សម្រាប់ការប្រឡងជ្រើសរើសគ្រូកម្រិតឧត្តម (ចរិញ្ញាបត្រ+១) ជំនាន់ទី២០

សមិយប្រឡង: ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៤

១. តើគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នាមានអ្វីខ្លះ? តើមានប្រទេសប៉ុន្មាននៅលើសកលលោកដែលសម្រេចបានទ្វេគោលដៅទាំងនេះ? (២.០០ពិន្ទុ)

គោលដៅទី១: ការតាំពារនិងការអប់រំកុមារក្ងច

គោលដៅទី២:សកលកម្មនៃការអប់រំបឋមសិក្សា

គោលដៅទី៣: ជំនាញរបស់យុវជននិងមនុស្សពេញវ័យ

គោលដៅទី៤: អក្ខរកម្មមនុស្សពេញវ័យ

គោលដៅទី៥:យុគភាពនិងសមភាពយេនឌ័រ

គោលដៅទី៦: គុណភាពនៃការអប់រំ

យោងតាមរបាយការណ៍ព័ត៌មាជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នានាឆ្នាំ២០១៣-២០១៤ បានបញ្ជាក់ថា:

លើសកលលោកមិនមានតំណាក់ចំនួនប្រទេសដែលសម្រេចបានតាមគោលដៅទាំងអស់នេះនៅត្រឹមឆ្នាំ ២០១៥ទេ។ប៉ុន្តែមានអត្រាភាគរយនៃចំនួនប្រទេសដែលនិងអាចសម្រេចបាន៥គោលដៅគឺ: គោលដៅទី១: ៩៨, គោលដៅទី២: ៩៦, គោលដៅទី៣:៩៦, គោលដៅទី៤: ២៩, គោលដៅទី៥:៧០(យុគភាពនៅកម្រិតបឋម)និង៥៦(យុគភាពនៅកម្រិតមធ្យមសិក្សាបឋមភូមិ)។

២. តើកត្តាអ្វីខ្លះដែលគ្រូយកចិត្តទុកដាក់ដើម្បីលើកកម្ពស់គុណភាពអប់រំ? (៨.០០ពិន្ទុ)

- គុណវុឌ្ឍិរបស់គ្រូបង្រៀន: ភាគរយគ្រូដែលទទួលបានការបណ្តុះបណ្តាលតាមស្តង់ដាជាតិ សញ្ញាបត្រកម្រិតជំនាញឯកទេស ភាសាបរទេស បច្ចេកវិទ្យា ជំនាញទំនាក់ទំនង ការថ្នាយសិស្ស(ចំណុះសាស្ត្រ និង គរុកោសល្យ)មានឥទ្ធិពលនិងមនសិការវិជ្ជាជីវៈ:

ន្តស។យោងតាមរបាយការណ៍របស់អង្គការUNESCO បញ្ជាក់ថា គុណវុឌ្ឍិរបស់គ្រូបង្រៀនមានទំនាក់ទំនងជាមួយលទ្ធផលសិក្សារបស់សិស្ស។របាយការណ៍នេះបានលើកឡើងពីយុទ្ធសាស្ត្រចំនួន៨ដើម្បីផ្តល់គ្រូល្អបំផុតក្នុងគោលបំណងឱ្យកុមារទទួលបានឱ្យការអប់រំប្រកបដោយគុណភាពគឺ:

១. គ្រូមានការជ្រើសរើសគ្រូដែលមានលក្ខណសម្បត្តិសមស្របទៅនឹងលក្ខណៈចម្រុះរបស់កុមារដែលត្រូវការទំនាក់ទំនងបង្រៀន

២.គ្រូគ្រូទទួលបានឱ្យការបណ្តុះបណ្តាលអំពីរបៀបផ្តល់ការតាំព្រះដល់សិស្ស(កុមារ)ដែលរៀនខ្សោយជាងគេចាប់ផ្តើមពីថ្នាក់ដំបូងទៅ

៣. មានគោលបំណងជម្លះវិសមភាពនៅក្នុងការរៀនសូត្រតាមរយៈការពង្រាយគ្រូដែលល្អបំផុតទៅតាមតំបន់ដែលជួបការលំបាកនៅក្នុងប្រទេស។

ភាសាក្រៅផ្តល់ឱ្យក្រុមហ៊ុនការលើកទឹកចិត្តគ្រប់ថ្នាក់ឱ្យបានសមស្រប ដើម្បីលើកទឹក
ចិត្តគេឱ្យបន្តបម្រើការងារនេះ និងជាជាងពុមាគ្រប់ប្រភេទជាអាចរៀនសូត្របានពីគ្រូភាសា
បរទេសក្នុងកាលៈទេសៈណាផ្សេងទៀត។

- កម្មវិធីសិក្សា:កម្មវិធីសិក្សាមានគុណភាពសមស្របតាមតម្រូវការ
- សម្ភារឧបទេស:ឯកសារសម្រាប់សិក្សាស្រាវជ្រាវសម្បូរបែប
- បរិស្ថានសិក្សា:

ដែលធ្វើបត្រូសិស្សតឹងតែងចង់ចូលសម្រាប់ធ្វើការពេលយកម្លៃវគ្គឧភាពគុណភាពអប់រំនិង
អតារសិក្សាត្រប់គ្រាន់តាមស្តង់ដាតអុកាសល្អ

- ជានាឱ្យបានទូរគុណភាពនៃការប្រឡងត្រប់តម្រិតៈគោលការណ៍នៃការប្រឡង
  ថ្នូរថាយុទ្ធសាស្ត្រពេលកម្លៃដើម្បីលើកតម្លៃសំការបង្រៀន និងរៀន។

៣.ហេតុអ្វីបានជានៅក្នុងសង្គមប្រជាជិតេយ្យគេឱ្យតម្លៃសមភាពបុគ្គលជាតន្លឹៈក្នុងការអភិវឌ្ឍស្ថាប័ននិង
ប្រទេសជាតិ?(៨.០០ពិន្ទុ)

សមភាពបុគ្គលគឺជាភាពស្មើគ្នារវាងសិទ្ធិរបស់បុគ្គលម្នាក់ៗប៉ុន្តែ
មិនតម្រូវឱ្យមនុស្សម្នាក់ៗត្រូវស្មើគ្នាគ្រប់កាលៈទេសៈទោះទេក្នុងសង្គមប្រជាជិតេយ្យ
សមភាពបុគ្គលកតន្លឹៈក្នុងការអភិវឌ្ឍប្រទេសតឹព្រោះ៖

- លុបបំបាត់ភាពរើសអើងតាមរយៈការទទួលបានទូរផលប្រយោជន៍ពីការចូលរួមការគាំទ្រជូនគ្នា
- ទទួលបានការសិក្សារៀនសូត្រពីសហសេវិករួមការងារក្នុងស្ថាប័ន
- ការទទួលបានទូរការទទួលស្គាល់តម្លៃនិងការគោរពស្របច្បាប់
- ទទួលបានឱកាសក្នុងការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន
- ការទទួលព័ត៌មានត្រប់គ្រាន់និងទាន់ពេលវេលា
- ការទទួលសិទ្ធិបញ្ចេញមតិយោបល់ និងទទួលយក/ស្តាប់យោបល់អ្នកដទៃ
- មានជំនឿជាក់ ទំនុកចិត្តនិងទំនួលខុសត្រូវលើសកម្មភាពរបស់ខ្លួន
- មានអារម្មណ៍កក់ក្តៅ ស្និទ្ធស្នាល ស្មោះត្រង់ការិៈតន់ក្នុងទំយស្ថាបនា
- មានឆន្ទៈចូលរួមក្នុងសក្ខភាពការងារបស់អង្គភាពឬស្ថាប័នរបស់ខ្លួន
- បង្កើតបានទូរវប្បធម៌ចែករំលែកចំណេះដឹងយ៉ាងទូលំទូលាយ
- បង្កើនសាមគ្គីភាព កក្តីភាពនិង
  ចំណងមិត្តភាពជាតម្លាំងស្នូលដែលអាចទាំមកទូរភាពជោគជ័យរបស់ស្ថាប័ននិង
  សង្គមជាតិមានការអភិវឌ្ឍ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងអប់រំ យុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ

ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២១

សម័យប្រឡង ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥

វិញ្ញាសា: អក្សរសាស្ត្រខ្មែរ រយៈពេល ១៨០នាទី

ឈ្មោះ.....លេខបន្ទប់.....លេខតុ.....ហត្ថលេខា.....

សំណួរ

១. បច្ចុប្បន្ននេះយើងឃើញថា មានកំហុសឆ្គងអក្ខរាវិរុទ្ធក្នុងការសរសេរអក្សរសាស្ត្រខ្មែរ ដែលជាបញ្ហាប្រឈមមួយគួរឱ្យកត់សម្គាល់។ តើបញ្ហាទាំងនេះបណ្តាលមកពីកត្តាអ្វីខ្លះ? ចូរពន្យល់។

២. ដូចម្តេចដែលហៅថា រូបារម្មណ៍ក្នុងអក្សរសិល្ប៍?

ក. ហេតុអ្វីបានជាគេថា រូបារម្មណ៍ជាលក្ខណៈពិសេសក្នុងស្នាដៃអក្សរសិល្ប៍?

ខ. ចូរប្រៀបធៀបរូបារម្មណ៍ក្នុងអត្ថបទពាក្យពាយ និងអត្ថបទកំណាព្យ។

៣. តើអក្សរសិល្ប៍មានសារប្រយោជន៍អ្វីខ្លះចំពោះប្រជាជនកម្ពុជា ក្នុងពេលដែលប្រទេសកម្ពុជាបានសមាហរណកម្មក្នុងតំបន់អាស៊ាន?

៤. តើអក្សរសិល្ប៍ប្រជាប្រិយខ្មែរ បានរួមចំណែកក្នុងការឆ្លុះបញ្ចាំងពីអត្តសញ្ញាណវប្បធម៌ដូចម្តេចខ្លះ? ចូរលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

៥. តើស្នាដៃអក្សរសិល្ប៍បានបង្ហាញពីសង្គមរសអ្វីខ្លះ? ចូរលើកឧទាហរណ៍ពីក្នុងស្នាដៃអក្សរសិល្ប៍មកបញ្ជាក់។

ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(ថ្នាក់ទី១)ជំនាន់ទី២១
សម៉ោងប្រឡងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥

ចំណាសារៈ ឧបករណ៍ទុកទៅ រយៈពេល ៥០នាទី

ឈ្មោះ.....លេខបន្ទប់.....លេខតុ.....ហត្ថលេខា.....

សំណួរ

១. តើយុទ្ធសាស្ត្រចម្បងមួយក្នុងចំណោមយុទ្ធសាស្ត្រចតុកោណគឺអ្វី? ចូរពន្យល់? (២.៥០ពិន្ទុ)

២. តើបច្ចុប្បន្ននេះក្រសួងអប់រំ យុវជន និងកីឡាមានចក្ខុវិស័យអ្វីខ្លះ? ចូរពន្យល់?(២.៥០ពិន្ទុ)

៣. បើអ្នកជាគ្រូបង្រៀនម្នាក់ តើមានករណីយកិច្ចត្រូវប្រតិបត្តិចំពោះខ្លួនឯងដូចម្តេចខ្លះ?(២.៥០ពិន្ទុ)

៤ តើភាពរដ្ឋាភិបាលបានសម្រេចយកថ្ងៃទីណា ជាទិវាជាតិអំណាន ក្នុងបុព្វហេតុអ្វីខ្លះ? ចូរពន្យល់។
(២.៥០ពិន្ទុ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឈ្មោះជនជាតិ ចិត្តកីឡា

ត្រឡប់ជ្រើសរើសបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ១) ជំនាន់ទី២១
សម័យត្រឡប់ទី ៖ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥
ចិញ្ចាសៅ ៖ ទស្សនាធំជួនៅ ល្បេះ:ពេល ៖ ៩០នាទី

អត្ថាកំណែ

១. តើយុទ្ធសាស្ត្រចម្បងមួយក្នុងចំណោមយុទ្ធសាស្ត្រចតុកោណគឺអ្វី? ចូររៀបរាប់។ (២,៥០ពិន្ទុ)
ចម្លើយ
(០,៥០) យុទ្ធសាស្ត្រចម្បងមួយក្នុងចំណោមយុទ្ធសាស្ត្រចតុកោណ គឺការអភិវឌ្ឍសិស្សរបស់។
(០,៥០) - ការកសាងសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្ស។
(០,៥០) - ការពង្រឹងគុណភាពអប់រំ
(០,៥០) - យកចិត្តទុកដាក់លើការអប់រំតម្រូវតម្លៃជាន់ក្រោយកម្រិតមូលដ្ឋានបឋមសិក្សា
(០,៥០) - ពង្រឹងភាពជាដៃគូរវាងថ្នែកសាធារណៈ និងថ្នែកឯកជនក្នុងការរៀបចំនិងប្រើប្រាស់ធនធានមនុស្ស។
កំណាត់សម្គាល់ ៖ បើសិនជាឆ្លើយសរសេរតំនឹងប្រហែលក្នុងចំណុចនីមួយៗទទួលបានពិន្ទុ (០,៣៣)

២. តើបច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យអ្វីខ្លះ? ចូរពន្យល់។ (៦,៥០ពិន្ទុ)
ចម្លើយ
បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យដូចជា ៖
(០,៧៥)+ ប្រែក្លាយមន្ទីរស្ថិរិយាកាន់តែមានសមត្ថភាពការងារ ៖
- មានកម្មវិធីសិក្សាជាក់លាក់
- មានសម្ភារៈសិក្សាគ្រប់គ្រាន់
- បណ្តុះបណ្តាលឱ្យមានចំណេះដឹង ចំណេះធ្វើ ឥរិយាបថ និងការចេះរស់នៅក្នុងសង្គមជាមួយគ្នា។
(០,៧៥)+ មានប្រសិទ្ធភាព មានភាពស៊ីវិល ៖
- បណ្តុះបណ្តាលឱ្យមានជំនាញច្បាស់លាស់
- ប្រើប្រាស់មនុស្សឱ្យចំជំនាញ
(០,៧៥) + មានការជឿជាក់ទុកចិត្តក្នុងការផ្តល់ និងតាំទ្រសេវាអប់រំដើម្បីរួមចំណែកអភិវឌ្ឍន៍សមត្ថភាពបុគ្គល
និងស្ថាប័នប្រកបដោយឧត្តមភាព ៖
- ផ្តល់ឱកាសជូនមនុស្សមានការសិក្សាគ្រប់ជ្រុង មានសមភាពយេនឌ័រ
- យកចិត្តទុកដាក់លើសុខភាពទាំងផ្លូវកាយ និងផ្លូវចិត្ត
- មានតម្លាភាព
- ផ្តល់ការលើកទឹកចិត្ត
(០,៧៥)សរុបមក ការបកស្រាយចំណុចទាំងបីខាងលើនេះ ជាចក្ខុវិស័យរបស់ក្រសួងអប់រំ។
កំណាត់សម្គាល់ ៖ បើសិនជាឆ្លើយតបស្រាយតាមរយៈចំណុចនីមួយៗទេ ក្រវែកពិន្ទុក្នុងមួយចំណុច (០,២៥)

៣. បើអ្នកជាគ្រូបង្រៀនម្នាក់ តើហេតុការណ៍មួយកំពុងប្រឈមចំពោះខ្លួនឯងថ្ងៃនេះគឺជាអ្វី? (២,៥០ពិន្ទុ)

ចម្លើយ

(០,៥០)- ត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈ: ការការពារសម្ងាត់ ដែលបានតំណាងដោយច្បាប់ និង បទបញ្ញត្តិនានា ដើម្បីផលប្រយោជន៍របស់អ្នកសិក្សា

(០,៥០) - ជៀបចំតំណែងការបង្រៀនដើម្បីតំណាងការពារឲ្យល្អសំដៅចានាគុណភាព។ និងប្រសិទ្ធភាពនៃការបង្រៀន

(០,៦៥)- គោរពបឹងគោរពយកឈ្នះ ចិត្ត និងសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងពេលប្រកបវិជ្ជាជីវៈ

(០,៦៥)- ស្តាប់ គំនិត្យ ឱ្យចំប្លន្ថាន ឬធ្វើឱ្យអាណាព្យាបាល អ្នកសិក្សាខ្វះទៅ មិនលម្អៀង មិនលើសឬមិនគ្រប់ លក្ខខណ្ឌ

(០,៦៥) - ក្លាក់ឆ្ងល់ក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៀតដើម្បីលើកកម្ពស់ខ្លួន

(០,៦៥) - មានការស្ងើយភាយតម្លៃទាំងសីលធម៌ អាត់ប្បកិរិយា និងលើការប្រកបវិជ្ជាជីវៈរបស់ខ្លួន

(០,៦៥) - ចូលរួម និងតាំទ្រគ្រប់សកម្មភាពអប់រំទោះក្នុងឬបរភាពណាក៏ដោយ

(០,៦៥) - និយ៉ាយស្តីដោយប្រុងប្រយ័ត្ន និងគិតដល់ប្រតិយ៉ាភាគ។

៤. តើភាជ្ជាកិច្ចាលបានសម្រេចយកថ្ងៃនៃណា ជាទិវាជាតិអំណាន ក្នុងបុព្វហេតុអ្វីខ្លះ? ចូរពន្យល់។ (២,៥ពិន្ទុ)

ចម្លើយ

(០,៥០)ភាជ្ជាកិច្ចាលបានសម្រេចយកថ្ងៃទី១១ ខែមីនា ដើម្បី ៖

(០,៥០) - បណ្តុះទម្លាប់អាន ជម្រុញវប្បធម៌អាន

(០,៥០) - លើកកម្ពស់សមត្ថភាពអាន

(០,៥០) - ការតែងនិពន្ធ រួមចំណែកការពារ និងពង្រឹងវប្បធម៌ខ្មែរ

(០,៥០) -វាជាជំនាញសំខាន់ក្នុងការបណ្តុះបំណិនជីវិតដើម្បីជួលភាពងាយស្រួលក្នុងការ

ភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨

អ្នកពាក់ព័ន្ធ

ឈឹម ភារ

បានឃើញ និងឯកភាព

ប្រធានកំណែ

ទេស ហាវ

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងអប់រំ យុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ

ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២២

សម័យប្រឡង ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦

វិញ្ញាសា អក្សរសាស្ត្រខ្មែរ រយៈពេល ០៣ម៉ោង

ឈ្មោះ.....លេខបន្ទប់.....លេខតុ.....ហត្ថលេខា.....

សំណួរ

១. តើភស្តុតាងអ្វីខ្លះ ដែលជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវពីអក្សរសាស្ត្រខ្មែរ?(២.០០ពិន្ទុ)

២. ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(១៩៩៣)បានកំណត់ថា ភាសា និងអក្សរសាស្ត្រដែលប្រើប្រាស់ជាផ្លូវការ គឺភាសា និងអក្សរសាស្ត្រខ្មែរ។ ចូរអ្នកពន្យល់ពីអត្ថន័យនេះ។(២.០០ពិន្ទុ)

៣. ហេតុដូចម្តេចបានជាគេចាត់ទុកថា មុខវិជ្ជាតែងសេចក្តី គឺជាមុខវិជ្ជាអនុវត្តក្នុងសាលារៀន? ហើយវាបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះសម្រាប់អ្នកសិក្សា?(២.០០ពិន្ទុ)

៤. តើការសិក្សាស្រាវជ្រាវពីអក្សរសិល្ប៍បស្ចឹមប្រទេសបានផ្តល់នូវអត្ថប្រយោជន៍អ្វីខ្លះសម្រាប់ការអភិវឌ្ឍសង្គមកម្ពុជាព្រមទាំងលើកជាឧទាហរណ៍បញ្ជាក់?(២.០០ពិន្ទុ)

៥. ចូរអ្នកបង្ហាញថា អក្សរសិល្ប៍ខ្មែរបានរួមចំណែកកសាងសុខដុមនីយកម្មនៃសង្គមវប្បធម៌កម្ពុជាដោយលើកជាឧទាហរណ៍ក្នុងរឿងណាមួយមកបញ្ជាក់ផង?(២.០០ពិន្ទុ)

ក្រសួងអប់រំយុវជន និងកីឡា
និងស្ថាប័នជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អក្សរកាំណែ

ប្រឡងជ្រើសរើសក្រុមគ្រូឧត្តមគរុកោសល្យ
ឆ្នាំ.១ ជំនាន់ទី ២២
មុខវិជ្ជាសារៈ ឧត្តមគរុកោសល្យ
រយៈពេល ៖ ៩០ នាទី

(ពិន្ទុ:២.០០) ១.សមីយតេរោសែនប្រទេសកម្ពុជាសម្រេចបានសមិទ្ធផលស្ថានឆ្លងទន្លេចំ
នៅឆ្នាំ ២០១៥ មានចំនួន ៥ ចូរនាងក្រោម៖

(០.៥០ពិន្ទុ) ស្ថានទី១ ស្ថានអ្នកលឿង ឬស្ថានគ្រឹបាសា ឬស្ថានកម្ពុជាធម្មជាតិ នៅខេត្តកណ្តាល

(០.៥០ពិន្ទុ) ស្ថានទី២ ស្ថានព្រោយចង្វាមីពីរ ឬស្ថានមិត្តភាពកម្ពុជា-ចិន នៅរាជធានីភ្នំពេញ

(០.៥០ពិន្ទុ) ស្ថានទី៣ ស្ថានព្រែកសំរោងឬស្ថានមិត្តភាពកម្ពុជា-ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល

(០.៥០ពិន្ទុ) ស្ថានទី៤ ស្ថានមេតង្គស្ទឹងព្រែង ឬស្ថានមិត្តភាពកម្ពុជា-ចិននៅខេត្តស្ទឹងត្រែង

(ពិន្ទុ:២.០០) ២. កត្តាដែលជំរុញឱ្យកំណែទម្រង់វិស័យអប់រំ លើការប្រឡងមធ្យមសិក្សា
ទុតិយភូមិរយៈពេលបីឆ្នាំកន្លងទៅ(២០១៤, ២០១៥ ,២០១៦)ទទួលបានផ្នែ
គុណភាពមាន៖

(០.២៥ពិន្ទុ) -គោរពគោលការណ៍នៃការប្រឡង(ច្បាប់ យុត្តិធម៌ តម្លាភាព លទ្ធផលទទួលយក
បាន)

(០.២៥ពិន្ទុ) -គណៈកម្មការមកប្រយោគត្រប់ប្រភេទ គោរពក្រមសីលធម៌ច្បាប់រិះ និងភាព
សុចរិត

(០.៥០ពិន្ទុ) -សហការយ៉ាងកក់ក្តៅពីអង្គភាពប្រឆាំងអំពើពុករលួយ (ACU) ដោយមាន
ការចូលរួមស្ម័គ្រចិត្តពីយុវជន (ស.ស.យ.ក)តាមរយៈការបំបំនតាមខេត្តផ្ទាល់

(០.២៥ពិន្ទុ) -ចូលរួមគាំទ្រពីគ្រប់មជ្ឈដ្ឋាន គ្រប់លំដាប់ថ្នាក់ទាំងថ្នាក់ដឹកនាំ មន្ត្រីអប់រំ
និងអជ្ញាធរ

(០.២៥ពិន្ទុ) -គោលនយោបាយអប់រំ (ចានាលទ្ធភាពសេវាអប់រំ លើកកម្ពស់គុណភាព
ភាពសក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់)

(០.២៥ពិន្ទុ) -សិស្សមានការយល់ដឹងពីច្បាប់ ទោសពិន័យ និងជឿជាក់លើសមត្ថភាពខ្លួន

(០.២៥ពិន្ទុ) -ដែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងឆ្នាំ២០១៩-២០១៨របស់ក្រសួងអប់រំ យុវជន និងកីឡា និងសមាហរណកម្មអាស៊ាន។

(ពិន្ទុ:៣.០០)៣. ប្រសិនបើខ្ញុំជាយថាគ្រូបង្រៀននាពេលខាងមុខ ខ្ញុំត្រូវចូលរួមក្នុងការអភិវឌ្ឍវិស័យអប់រំប្រកបដោយចីរភាពដូចតទៅ៖

★ ចម្បងម៉ឺ

(០.២៥ពិន្ទុ) -ចូលរួមលើកកម្ពស់ និងអភិឌ្ឍវប្បធម៌

(០.២៥ពិន្ទុ) -អភិរក្ស និងអភិឌ្ឍតំបន់ទេសចរណ៍វប្បធម៌

(០.២៥ពិន្ទុ) -បណ្តុះគំនិតស្មារតីសិស្សឱ្យចេះស្រលាញ់ និងលើកតម្កើងវប្បធម៌ជាតិ ទាំងរូបី និងអរូបី

★ សេដ្ឋកិច្ច

(០.២៥ពិន្ទុ) -បង្រៀនសិស្សដោយផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្ត

(០.២៥ពិន្ទុ) -បណ្តុះបំលាងវិជ្ជាជីវៈ និងបំលាងជីវិត

(០.២៥ពិន្ទុ) -ផ្តល់ចំណេះដឹងទូទៅ ជំនាញ សុខភាពផ្លូវចិត្ត និងផ្លូវកាយល្អ

(០.២៥ពិន្ទុ) -មានគំនិតច្នៃប្រឌិតលើជំនាញទៅតាមតម្រូវទីផ្សាររបស់សង្គម។

★ សង្គម

(០.២៥ពិន្ទុ) -មានចំណាប់អារម្មណ៍ចិញ្ចឹត្តិការណ៍សង្គម

(០.២៥ពិន្ទុ) -អភិវឌ្ឍសមត្ថភាពខ្លួនឯងឱ្យបានទូលំទូលាយ (ភាសាបរទេស ជំនាញឯកទេស ព័ត៌មានវិទ្យា សីលធម៌...)

★ បរិស្ថាន

(០.២៥ពិន្ទុ) -បរិស្ថានអប់រំ (បរិយាកាសថ្នាក់រៀន)

(០.២៥ពិន្ទុ) -បរិស្ថានមនុស្ស (សុខភាពផ្លូវចិត្ត)

(០.២៥ពិន្ទុ) -បរិស្ថានធម្មជាតិ (ព្រៃប្រឹក្សា បឹងបួរ...)

(ពិន្ទុ:៣.០០)៤. វិស័យអប់រំមានតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិពីព្រោះ៖

(០.៥០ពិន្ទុ) -គ្រូបង្រៀនជាវិស្វកររៃអង្គាលឹង ជាគម្រូ ជាអ្នកអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសីលធម៌សង្គមល្អ ស្មោះត្រង់ មានឧត្តមគតិជាតិ និងជំនាញ...

(០.៥០ពិន្ទុ) -ធនធានមនុស្សចាំបាច់ត្រូវមានសមត្ថភាពផ្នែកចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេស វិទ្យាសាស្ត្រសង្គម សុខភាពផ្លូវចិត្តរឹងមាំ។ ឧ. វិស្វករ គ្រូពេទ្យ គ្រូបង្រៀន....

(០.២៥ពិន្ទុ) -ចូលរួមក្នុងការកសាងសតិបញ្ញារបស់មនុស្សជាតិក្នុងសង្គម

(០.២៥ពិន្ទុ) -បណ្តុះបណ្តាលសមត្ថភាពចំណេះដឹង ជំនាញ អនុវត្ត ការជ្រាស្រ័យទាក់ទង

ក្នុងសង្គម។

(ខ.២៥ពិន្ទុ) -ចូលរួមចំណែកអភិវឌ្ឍសមត្ថភាពខ្លួនឯង និងអ្នកនៅជុំវិញជាប្រចាំ

(ខ.២៥ពិន្ទុ) -បណ្តុះគំនិតសិស្សឱ្យយល់ដឹងពីនិន្នាការនៃការអប់រំទាំងក្នុង និងក្រៅប្រទេស

(ខ.២៥ពិន្ទុ) -អប់រំមនុស្សឱ្យទទួលបានទូវជំនាញ សមត្ថភាព តម្លៃ និងចំណេះដឹងឆ្លើយតបទៅនឹងទីផ្សារសង្គម។

(ខ.២៥ពិន្ទុ) -តួនាទីអប់រំមនុស្សទាំងក្នុង និងក្រៅប្រព័ន្ធព្រមទាំងតាមសហគមន៍ឱ្យមានការយល់ដឹងពីបំណាងជីវិត។

(ខ.៥០ពិន្ទុ) សន្និដ្ឋាន៖ ការណាធនធានមនុស្សមានគុណភាព និងប្រសិទ្ធភាពនោះ ប្រទេសជាតិពិតជាមានការអភិវឌ្ឍសេដ្ឋកិច្ចមែន។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៦

ប្រធានកំណែ

សាំង សុចិន្តា